ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ៤៣០/១៨

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែកញ្ញា និងទិសដៅខែតុលា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែកញ្ញា ឆ្នាំ២០១៨នេះ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬ ទេសន្តរប្រវេសន៍ នៅតែបន្តមាន ទោះបីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក និងទោះបីរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំបីម៉ឺននាក់ហើយក៏ដោយ។ ពលរដ្ឋខ្មែរនៅតែបាននិងកំពុងចូលទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានិភ័យនានា ដូចជាការបញ្ជូនត្រឡប់មកវិញ ត្រូវឃាត់ខ្លួន ដាក់ទោសទណ្ឌ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាក់ និងពេលវេលា ជាដើម។ល។ យុវជនមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ថ្មីៗនេះ រូបភាពនៃអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏កើតឡើងនូវសកម្មភាពផលិត និងចែកចាយរូបភាពអាសអាភាស យ៉ាងអាណាធិបតេយ្យ ក្នុងគោលដៅពាណិជ្ជកម្មផ្លូវភេទ នៅតាមតំបន់ទេចរណ៍ និងតំបន់អភិវឌ្ឍន៍ថ្មីៗ ដូចជានៅខេត្តព្រះសីហនុ រាជធានីភ្នំពេញ និងសាយភាយទៅតាមទីជនបទមួយចំនួនទៀត។

ដើម្បីឆ្លើយតបទៅនឹងបញ្ហា ដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការ ជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ច នៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ការអនុវត្តយុទ្ធសាស្ត្រ នៃផែនការសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១. <u>សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖</u>

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. <u>សន្ធិសញ្ញាកំពុងរៀបចំ៖</u>

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - ស្តីពី "បញ្ជូនទណ្ឌិត"
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.៣. <u>អនុស្សរណៈកំពុងរៀបចំ៖</u>

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.៤. <u>បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖</u>

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តល័ក្ខខ័ណ្ឌ ការងារកម្មករការងារផ្ទះ"។
- ក្រសួងអប់រំ យុវជន និងកីឡា៖ ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ

រដ្ឋបាលខេត្តចំនួន៣ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៧.៦២០ក្បាល (បាត់ដំបងចំនួន ៥.៦២៩ក្បាល បន្ទាយមានជ័យ ១.៤៤៥ក្បាល និងខេត្តប៉ៃលិន ៥៤៦ក្បាល) ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែកញ្ញា ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន ៣.៨៥៥លើក មានអ្នកចូលរួមសរុបចំនួន ២២៦.៩៣៩នាក់ (បើប្រៀបធៀបនឹងខែសីហា មានចំនួន ២៣១.៩០៧នាក់) មានការថយចុះចំនួន៤.៩៦៨នាក់ ស្មើនឹង ២,១៨% ក្នុងនោះស្ត្រីមានចំនួន ១១៨.២១៧នាក់។ (ឧបសម្ព័ន្ធទី១)

### ខ.៣. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- លេខាធិការដ្ឋានគ.ជ.ប.ជ បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន ៤៦លើក (ខេត្តកោះកុង ៣១លើក និងខេត្តសៀមរាប ១៥លើក)។
- ខេត្តបាត់ដំបង អង្គការ **Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក ៦៨នាក់ ស្រី ២៣នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

### ខ.៤. វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

#### ខ.៤.១. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាល រាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់ តាមគោលដៅទទួលបានលទ្ធផលដូចខាងក្រោម ៖

- កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្តៈ តាកែវ កែប មណ្ឌលគិរី ព្រះសីហនុ កោះកុង ក្រចេះ ឧត្តរមានជ័យ ស្វាយរៀង កណ្តាល និងរតនគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៦៥៩គោលដៅ មានមនុស្សចំនួន ២៦.១៧៨នាក់ (ស្រី ១៧.០៥៩នាក់)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ សរុបចំនួន ៧៥គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន ៩២លើក ខេត្តអនុវត្តមានៈ (ស្វាយរៀង ព្រះវិហារ កំពង់ស្ពឺ ឧត្តរមានជ័យ ស្ទឹងត្រែង និងព្រៃវែង)។
- ខេត្តកំពង់ចាម ស្នងការដ្ឋាននគរបាល បានចុះចលនាដាក់បណ្តាញភ្នាក់ងារ ចំនួន ៤៩នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី និងបណ្តាញសហគមន៍។

ខ.៥. វិធានការការប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់

ខ.៥.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣៦២.៤៩៥នាក់ (ស្រី ១៥៩.៧៤៦នាក់) អនីតិជន ៩.៤៨៨នាក់ (ស្រី ៣.៥៨០នាក់) ក្នុងនោះស្របច្បាប់ចំនួន១៩៨.២៦៥នាក់ (ស្រី ៩១.៦៧១នាក់) អនីតិជន ៦៥៣នាក់ (ស្រី ២៧៧នាក់) មិនស្របច្បាប់ចំនួន ១៦៤.២៣០នាក់ (ស្រី ៦៨.០៧៥នាក់) អនីតិជន ៨.៨៣៥នាក់ (ស្រី ៣.៣០៣នាក់) បើប្រៀបធៀបនឹងខែមុន គឺខែសីហាមានចំនួន ៣១១.៧៨៦នាក់ មានការកើនឡើងចំនួន ៥០.៧០៩នាក់ ស្មើនឹង ១៦,២៦%។

ខ.៦. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈ ការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ១២៦គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ចំនួន ១៥នាក់ ដែលទៅរស់នៅជាមួយស្វាមី ឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីអង្គភាពចំនួន៨ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលខេត្តៈ បាត់ដំបង កំពង់ចាម ក្រចេះ មណ្ឌលគិរី សៀមរាប និងព្រះសីហនុ។

គ.១. ការងារអនុវត្តច្បាប់

គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន ១៥/១៤ករណី (បើប្រៀបធៀបនឹងខែសីហា កើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៨នាក់ (ស្រី ១០នាក់) ជនសង្ស័យជាអនីតិជន ០២នាក់ និងជាជនបរទេស ចំនួន ១០នាក់ (សញ្ជាតិចិន)។ សង្គ្រោះជនរងគ្រោះ ចំនួន ៤៥នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០៤នាក់ អាយុ១៥ឆ្នាំ-១៧ឆ្នាំ ០៧នាក់ និងអាយុ១៨ឆ្នាំឡើង ៣៤នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២៦នាក់ អង្គការ ០១នាក់ និងប្រគល់ទៅគ្រួសារ ១៨នាក់)។

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៥/០៣ករណី (បើប្រៀបធៀបនឹងខែសីហា កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៨នាក់ (ស្រី ០៤នាក់) និងសង្គ្រោះជនរងគ្រោះចំនួន ១៣នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥ឆ្នាំ-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ០៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៦នាក់ អង្គការ ០១នាក់ និងប្រគល់ទៅគ្រួសារ ០៦នាក់។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០២ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០២ |
| -អំពើអូសទាញពេស្យាចារកុមារ | ០១ | ០២ |
| *សរុប* | *០៥ ករណី* | *០៨ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១០/១១ករណី (បើប្រៀបធៀបនឹងខែសីហា ថយចុះ ០១ករណី) ឃាត់ខ្លួនជនសង្ស័យ ចំនួន ២០នាក់ (ស្រី ០៦នាក់) ជនសង្ស័យជាអនីតិជន ចំនួន ០២នាក់ និងជាជនបរទេស ចំនួន ១០នាក់ (សញ្ជាតិចិន)។ សង្គ្រោះជនរងគ្រោះចំនួន ៣២នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០៣នាក់ អាយុ១៥ឆ្នាំ-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ២៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២០នាក់ និងប្រគល់ទៅគ្រួសារ ១២នាក់។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ហារកម្ម | ០៤ | ១២ | ចិន១០ |
| -សញ្ហារកម្ម (មានអនីតិជន) | ០២ | ០៣ | |
| -សញ្ហារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | |
| *សរុប* | *១០ ករណី* | *២០ នាក់* | *១០ នាក់* |

## **ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ**

ឃ.១. <u>ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងជនសង្ស័យ</u>

ឃ.១.១. <u>ការទទួលជនសង្ស័យរងគ្រោះ</u>

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ៤៦នាក់ ក្នុងនោះមកពី៖

- ប្រទេសវៀតណាម ចំនួន ៣៣នាក់
- ប្រទេសចិន ចំនួន ១៣នាក់។

យោងរបាយការណ៍ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១២៤លើក មនុស្សចំនួន ២.៤០៤នាក់ (ស្រី ៧៨៩នាក់ កុមារ ២១៩នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន ៣៧លើក មនុស្សចំនួន ១១៩នាក់ (ស្រី ៤៥នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ៨៧លើក មនុស្សចំនួន ២.២៨៥នាក់ (ស្រី ៧៤៤នាក់ កុមារ ២១៩នាក់)។

ឃ.១.២. ការទទួល និងសម្ភាសន៍ជនរងគ្រោះ

យោងរបាយការណ៍ **អគ្គស្នងការដ្ឋាននគរបាលជាតិ** (ក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះ សរុបចំនួន ២៧នាក់ (ស្រី ២៣នាក់) តាមការសម្ភាសន៍បានឲ្យដឹងថាទៅតាមរយៈមេខ្យល់ទាំងអស់។ ក្នុងនោះមកពី៖

- ប្រទេសចិន ចំនួន ២៣នាក់
- ប្រទេសម៉ាឡេស៊ី ចំនួន ០៣នាក់
- ប្រទេសថៃ ចំនួន ០១នាក់។

**របាយការណ៍ពីស្ថានភាព ៖**

**ស្នងការដ្ឋាននគរបាលខេត្ត** តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ៣.០៨៦នាក់ (ស្រី ៦៩៤នាក់) អនីតិជន ២០០នាក់ ក្នុងនោះមាន៖

+ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ចំនួន ២.៩០៣នាក់ (ស្រី ៦២៣នាក់) អនីតិជន ១៨១នាក់ ក្នុងនោះមានចំនួន ២៣នាក់ (ស្រី ០៧នាក់) ត្រូវអាជ្ញាធរថៃ ឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែ មុននឹងបញ្ជូនមកកម្ពុជាវិញ។
  - ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ចំនួន ១៤៧នាក់ (ស្រី ៥៤នាក់) អនីតិជន ០៧នាក់។
  - ស្នងការដ្ឋាននគរបាលខេត្តកោះកុង ចំនួន ២២នាក់ (ស្រី ០៩នាក់) អនីតិជន ០២នាក់។
+ តាមច្រកព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម
  - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ចំនួន ១៤នាក់ (ស្រី ០៨នាក់) អនីតិជន ១០នាក់។

**ដោយឡែក អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន ១.៨៦១នាក់ (ស្រី ៥៦៧នាក់) អនីតិជន ១៤៧នាក់ ក្នុងនោះមាន៖

- ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ១.៥៩៤នាក់ (ស្រី ៥៣៣នាក់) អនីតិជន ១៤៦នាក់
- ច្រកអន្តរជាតិដូង ចំនួន ២៦៧នាក់ (ស្រី ៣៤នាក់) អនីតិជន ០១នាក់។

**ការគ្រប់គ្រងជនបរទេស៖**

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន ៥៧លើក មនុស្សចំនួន ១៦៣នាក់ ស្រី ២៦នាក់ មាន ៣៩សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋាន ចំនួន ៣៥លើក មនុស្សចំនួន ៥៩នាក់ ស្រី ០៤នាក់ មាន ១៤សញ្ជាតិ។

- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន ២២លើក មនុស្សចំនួន ១០៤នាក់ ស្រី ២២នាក់ មាន ២៥សញ្ជាតិ។

២. ករណីស្នាក់នៅខុសច្បាប់

- ហួសទិដ្ឋា ០២លើក មនុស្សចំនួន ០៦នាក់ ស្រី ០១នាក់ ០២សញ្ជាតិ (នីហ្សេរីយ៉ា ០៤នាក់ និង សឹង្ហបុរី ០២នាក់)។
- លួចឆ្លងដែនខុសច្បាប់ ០១លើក មនុស្សចំនួន ០២នាក់ សញ្ជាតិថៃ។
- គ្មានឯកសារគ្រប់គ្រាន់ ០១លើក មនុស្សចំនួន ៣៦នាក់ ស្រី ១៣នាក់ សញ្ជាតិវៀតណាម។
- គ្មានលិខិតឆ្លងដែន ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិអូស្ត្រាលី។
- គ្មានប័ណ្ណការងារ ០១លើក មនុស្សចំនួន ០៦នាក់ ស្រី ០២នាក់ សញ្ជាតិចិន។

៣. ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍សរុប ចំនួន ១២៩គ្រួសារ មនុស្សចំនួន ៣៧៦នាក់ ស្រី ១៨៣នាក់ សញ្ជាតិវៀតណាម ក្នុងនោះ ដកហូតឯកសារ បានចំនួន ៤០៥ឯកសារ មាន ០៦ប្រភេទ។

## III. ការលើកកម្ពស់សមត្ថភាព

### ក. ក្នុងប្រទេស

ក.១. ការងារបណ្តុះបណ្តាលក្នុងប្រទេស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នអនុវត្ត និងលេខាធិការដ្ឋាន រាជធានី-ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍ នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន០៦វគ្គ មានសិក្ខាកាម ចូលរួមចំនួន១៦០នាក់ ក្នុងនោះមានស្ត្រី៣០នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ ៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចាត់បញ្ជូនអគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីចូលរួមជាគ្រូបង្គោល ក្នុងវគ្គបណ្តុះ បណ្តាលបំប៉នជំនាញប្រឆាំងអំពើជួញដូរមនុស្ស ជូនដល់៖<br>- នាយនគរបាលប៉ុស្តិ៍រដ្ឋបាល នៃអធិការដ្ឋាននគរបាល ក្រុងតាខ្មៅ នៃស្នងការដ្ឋាននគរបាល ខេត្តកណ្តាល អ្នកចូលរួមចំនួន៣២នាក់ ស្រី០៨នាក់។<br>- នាយនគរបាលប៉ុស្តិ៍រដ្ឋបាល នៃអធិការដ្ឋាននគរបាល ខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ អ្នកចូលរួមចំនួន៣០នាក់ ស្រី០៦នាក់។ | ០២ | ៦២ | ១៤ |
| ២ | **ខេត្តបាត់ដំបង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** បើកវគ្គបណ្តុះបណ្តាល ស្តីពីលក្ខខណ្ឌការងារ និងសន្តិសុខការងារ នៃសហគ្រាសគ្រឹះស្ថាន និងក្រុមហ៊ុនផ្នែកសេវាកម្មឡាន្ត។ | ០២ | ៤០ | ១៦ |

| | | | | |
|---|---|---|---|---|
| ៣ | ខេត្តសៀមរាប លេខាធិការដ្ឋាន គ.ខ.ប.ជ ៖<br>- អង្គការFriend International វគ្គបណ្តុះបណ្តាលចំនួន០៤វគ្គ៖<br>○ ស្តីពីការពង្រឹងសមត្ថភាពភ្នាក់ងារសុវត្ថិភាពកុមារ ដល់បុគ្គលិក អ្នកចូលរួមចំនួន៣២នាក់។<br>○ ស្តីពីការលើកកម្ពស់កិច្ចការពារកុមារ (អាហារដ្ឋាន, អ្នករត់ម៉ូតូម៉ាកកង់បី អ្នកលក់បន្លែ ផ្លែឈើ) អ្នកចូលរួមចំនួន២៦នាក់។ | ០២ | ៥៨ | |
| សរុប | | ០៦ | ១៦០ | ៣០ |

ក.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** ដោយទទួលបានការឧបត្ថម្ភពី **អង្គការ វិនរ៉ក់កម្ពុជា** បានរៀបចំសិក្ខាសាលា ស្តីពី "**ការពង្រឹងការងារបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្សនៅកម្ពុជា**" ចំនួន **១០**វគ្គ នៅក្រុង-ស្រុក ទាំង**១០** ក្នុងខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមមានៈ នាយក-នាយិកា មកពីសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ មន្ត្រីរដ្ឋបាល ក្រុង-ស្រុក មន្ត្រីការិយាល័យអប់រំ ក្រុង-ស្រុក និងមន្ត្រីសមត្ថកិច្ច មូលដ្ឋានពាក់ព័ន្ធ សរុបចំនួន **៥៨៥**នាក់ ស្រី **១១១**នាក់។

ក.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ៤៥លើក មានអ្នកចូលរួមសរុប៤១៣នាក់ មានស្រី៣៥៩នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១២លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន៣៣លើក។ (ឧបសម្ព័ន្ធទី២)

## ខ. ក្រៅប្រទេស និងថ្នាក់អន្តរជាតិ

ខ.១. វគ្គបណ្តុះបណ្តាល

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចាត់បញ្ជូននាយនគរបាលចំនួន ០៣រូប ដើម្បីទៅចូលរួម៖

- ○ វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់សម្រាំង ដើម្បីបង្ក្រាបបទល្មើសលើកុមារ តាមប្រព័ន្ធអ៊ិនធើណេត ប្រទេសថៃ។
- ○ វគ្គបំប៉នការងារដឹកនាំសម្រាប់ថ្នាក់នាយកដ្ឋាន ស្នងការ និងការិយាល័យ ប្រទេសវៀតណាម។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ចំនួន០១រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ប្រតិបត្តិការគ្រប់គ្រងការធ្វើសមាហរណកម្ម ព្រំដែន ទីក្រុងម៉ានីល នៃប្រទេសហ្វីលីពីន។

ខ.២. កិច្ចប្រជុំ និងសិក្ខាសាលា ជាអន្តរជាតិ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដឹកនាំគណៈប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកោះកុង ដើម្បីអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរ ខេត្តត្រាត ប្រទេសថៃ។

- ខេត្តមណ្ឌលគិរីៈ លោកឧត្តមសេនីយ៍ទោ ស្នងការនគរបាលខេត្ត បានដឹកនាំគណៈប្រតិភូ ចំនួន ០២លើក ដើម្បីចូលរួមប្រកិច្ចប្រជុំ បូកសរុបលទ្ធផលការងារសហប្រតិបត្តិការ ស្តីពីការរក្សាសន្តិសុខព្រំដែន និងការបង្ការ ទប់ស្កាត់បទល្មើសផ្សេងៗ នៅបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនខេត្តដាក់ណុង ប្រទេសវៀតណាម។

ខ.៣. <u>សន្និសីទ</u>

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ចំនួន ០២រូប ដើម្បីទៅចូលរួមសន្និសីទ ស្តីពីការប្រយុទ្ធប្រឆាំងអំពើភេវរកម្មអាស៊ាន នៃប្រទេសសឹង្ហបុរី។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់ៈ

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។

- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែតុលា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...........................ខែ...............ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ខែកញ្ញា ឆ្នាំ២០១៨**

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 161 លើក | 8,160 នាក់ | 4,661 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 304 លើក | 9,696 នាក់ | 5,238 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំនានាដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 27 លើក | 4,367 នាក់ | 1,761 នាក់ |
| 3 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 626 លើក | 48,624 នាក់ | 24,598 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | | 357 លើក | 15,858 នាក់ | 7,562 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 176 លើក | 8,445 នាក់ | 4,700 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 270 លើក | 19,434 នាក់ | 10,792 នាក់ |
| 5 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត | 389 លើក | 21,435 នាក់ | 12,683 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 125 លើក | 9,024 នាក់ | 540 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 5 លើក | 1,065 នាក់ | 497 នាក់ |
| 6 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាលក្រុង ស្រុក | 16 លើក | 752 នាក់ | 367 នាក់ |
| 7 | ខេត្តតាកែវ | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 158 លើក | 5,723 នាក់ | 2,515 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | ខេត្តប៉ៃលិន | ផ្សព្វផ្សាយ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និង ស្នងការដ្ឋាននគរបាលខេត្ត | 53 លើក | 2,421 នាក់ | 1,051 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដល់ អាជ្ញាធរមូលដ្ឋាន អធិការ-អធិការរង នាយ-នាយរងប៉ុស្តិ៍ មន្ត្រីនគរបាល និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 45 លើក | 1,998 នាក់ | 837 នាក់ |
| 9 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 383 លើក | 20,382 នាក់ | 11,517 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងផ្សព្វផ្សាយ ច្បាប់ស្តីពីការជួញដូរមនុស្ស ដោយបញ្ជ្រាបតាមរយៈកិច្ចប្រជុំ ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត រដ្ឋបាលស្រុក មន្ទីរកិច្ចការនារីខេត្ត | 515 លើក | 36,264 នាក់ | 21,179 នាក់ |
| 10 | ខេត្តរតនគិរី | ផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ស្តីពីការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់។ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | 11 លើក | 130 នាក់ | 51 នាក់ |
| 11 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 220 លើក | 10,586 នាក់ | 5,895 នាក់ |
| 12 | ខេត្តព្រៃវែង | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់រាល់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ និង ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ក្រុមាការងារថ្នាក់ភូមិ ឃុំ ស្រុក និងអង្គការសម្ព័ន្ធចាប់ដៃ | 1 លើក | 1,301 នាក់ | 965 នាក់ |
| 13 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីពីកិច្ចការពារ ការទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពាន អាជីវកម្មផ្លូវភេទ និងយុត្តិធម៌អនីតិជន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរសង្គមកិច្ចខេត្ត | 5 លើក | 288 នាក់ | 202 នាក់ |
| 14 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 5 លើក | 223 នាក់ | 164 នាក់ |
| 15 | ខេត្តមណ្ឌលគិរី | ផ្សព្វផ្សាយ អំពើច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផលប៉ះពាល់នៃ ការធ្វើចំណាកស្រុកដោយខុសច្បាប់របស់ប្រជាពលរដ្ឋ ការចែកចាយ ឬ បិតរូបភាពអាសអាភាស ដល់អធិការក្រុងស្រុក ទាំង ០៥ និងប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង២១។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 479 នាក់ | 315 នាក់ |
| 16 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់កងកម្លាំងមន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការទស្សនៈពិភពលោក | 2 លើក | 284 នាក់ | 127 នាក់ |

សកម្មភាពសរុបចំនួន: 3,855 លើក

មនុស្សសរុបចំនួន: 226,939 នាក់

ស្រីសរុបចំនួន : 118,217 នាក់

# ឧបសម្ព័ន្ធទី២

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤៥លើក) មនុស្សចំនួន៤១៣នាក់ (ស្រី៣៥៩នាក់)

| **ស្ថាប័ន សម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិ<br>គ.ជ.ប.ជ | សម្របសម្រួលចំនួន១២លើក<br>លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដឹកនាំកិច្ចប្រជុំ និងបានអញ្ជើញ ៖<br>- ពិភាក្សាលើ អនុក្រឹត្យ ២៧៣ អនក្រ.បក និងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាបន័ សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីរកគន្លឹះ បំពេញបន្ថែមនូវចន្លោះខ្វះខាត។<br>- ពិភាក្សានិង ផ្តល់យោបល់អំពីពង្រាងសេចក្តីសម្រេច ស្តីអំពីការបង្កើតក្រុមការងារប្រចាំការទទួលពលករ ពលការនីកម្ពុជាខុសច្បាប់ប្រចាំ ខេត្តបន្ទាយមានជ័យ។<br>- សំណួរវាយតម្លៃ គ.រ.ប.ជ/គ.ខ.ប.ជ លើកសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨<br>- ចុះសាកសួរសុខទុក្ខស្វែងយល់អំពីស្ថានភាពកម្មករ-ពលករលើទូកនេសាទ និងជួបពិភាក្សាការងារជាមួយមន្ត្រីទទួលបន្ទុកការងារនៅក្នុងខេត្តត្រាត ប្រទេសថៃ។<br>- ជួបសំណេះសំណាលជាមួយកងកម្លាំងនគរបាលការពារតាមច្រកព្រំដែនកម្ពុជា-ថៃ និងច្រក៤០០ សំឡូត។<br><br>១ . <u>ក្រុមជំនួយការបង្ការ ទប់ស្កាត់:</u><br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន រ៉ូ** អគ្គលេខាធិការរង បានអញ្ជើញដឹកមន្ត្រីក្រុមការងារជំនួយកិច្ចការបង្ការ ទប់ស្កាត់ ពិភាក្សាបន្តលើសំណួរវាយតម្លៃ គ.រ.ប.ជ/គ.ខ.ប.ជ លើសកម្មភាពបង្ការ ទប់ស្កាត់ ឆ្នាំ២០១៧-២០១៨ ដើម្បីត្រៀមដាក់បញ្ចូលជាកម្រងសំណួររួម សម្រាប់ជូនភ្ជាប់ទៅរាជធានី-ខេត្ត ឲ្យឆ្លើយតបត្រូវតាមសកម្មភាពដែលពួកគាត់ដែលធ្វើរួច។<br><br>២. <u>ក្រុមការងារអនុវត្តច្បាប់</u><br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង បានសម្របសម្រួលណែនាំនីតិវិធីៈ<br>• លើករណីនាំនារីខ្មែរ ចំនួន០២នាក់ទៅប្រទេសចិន ត្រូវបានសមត្ថកិច្ចវៀតណាមចាប់ខ្លួនបាន រួចបញ្ជូនមកអគ្គកុងស៊ុលខ្មែរប្រចាំនៅទីក្រុងហូជីមិញ រីឯស្ត្រីអ្នកនាំផ្លូវ ត្រូវបានសមត្ថកិច្ចវៀតណាមឃាត់ខ្លួន ដោយប្រាប់ទៅមន្ត្រីជំនាញសហការជាមួយសមត្ថកិច្ចខេត្ត និងមន្ត្រីកុងស៊ុលខ្មែរប្រចាំនៅទីក្រុងហូជីមិញ ដើម្បីប្រគល់ទទួលនារីរងគ្រោះទាំងពីរនាក់ សម្ភាសន៍កំណត់អត្តសញ្ញាណ បើកការស៊ើបអង្កេតបឋម និងអនុវត្តនីតិវិធីចាត់ការតាមច្បាប់។<br>• លើករណីនាំចេញដោយមិនស្របច្បាប់ទៅប្រទេសចិនបង្ខំរៀបការ ផ្ទុយពីឆន្ទៈ។<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមប្រជុំស្តីពីការពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារប្រចាំការ ទទួលពលករ ពលការីនីខុសច្បាប់ ប្រចាំខេត្តបន្ទាយមានជ័យ។<br>- ក្រុមជំនួយកិច្ចការអនុវត្តន៍ច្បាប់ បានសម្របសម្រួលធ្វើកំណត់ហេតុបណ្តឹងបងប្រុសជនរងគ្រោះ ដែលត្រូវជាប្អូនរបស់ស្ត្រីដែលបានបាត់ខ្លួននៅប្រទេសម៉ាឡេស៊ី។ |

| | |
|---|---|
| | ៣. <u>ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ</u><br>- បានតាមដាន និងស្រង់ទិន្នន័យពលកររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស បានសហការជាមួយអាជ្ញាធរនៅតាមតំបន់ មានចំនួន៥៥នាក់ (ស្រី៣១នាក់) មកពី ៖<br>• ប្រទេសម៉ាឡេស៊ី ចំនួន ២២នាក់ (ស្រី០១នាក់) ធ្វើការខុសច្បាប់ និងទ្រាំការងារមិនបាន<br>• ប្រទេសវៀតណាម ចំនួន ៣១នាក់ លក់ឆ្នោត និងរស់នៅខុសច្បាប់<br>• ប្រទេសចិន ចំនួន ០២នាក់ (ស្រី)។ រៀបការខុសច្បាប់។<br>៤. <u>ក្រុមជំនួយកិច្ចការយុត្តិធម៌:</u><br>- បានទំនាក់ទំនង ក្រសួងយុត្តិធម៌ ដើម្បីសុំរបាយការណ៍ប្រចាំខែ និងត្រីមាសទី៣។<br>៥. <u>ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:</u><br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមប្រជុំជាមួយក្រុមការងារអន្តរក្រសួង ទាក់ទងនឹងបញ្ហាស្ត្រីទាំង៣២នាក់ ដែលឃាត់ខ្លួនក្នុងករណីពពោះជំនួស។<br>- មន្ត្រីក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ បានចូលរួមកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគ.ជ.ប.ជ និងក្រុមការងារខេមមីតកម្ពុជា បានប្រជុំពិភាក្សា និងសម្រេច លើខ្លឹមសាររបាយការណ៍ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រុមការងារសហប្រតិបត្តិការអន្តរជាតិ គ.ជ.ប.ជ រយៈពេល៥ឆ្នាំ ២០១៤-២០១៨ និងទិសដៅការងារត្រូវអនុវត្តបន្ត ក្រោមអធិបតីភាពលោកជំទាវ សាន្ត អុរណ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី នៅទីស្តីការក្រសួងកិច្ចការនារី។<br>- លោកវរសេនីយ៍ឯក អ៊ិន មាន បានចូលរួមសិក្ខាសាលាបូកសរុបលទ្ធផល គម្រោង និងការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃគម្រោងពង្រឹងយន្តការការពារកុមារ នៅតាមសហគមន៍ នៅភោជនីដ្ឋានសួនអេដែន រាជធានីភ្នំពេញដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធិផលការងាររយៈពេល២ឆ្នាំ។<br>៦. <u>ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:</u><br>- បានទំនាក់ទំនង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំរបាយការណ៍ ត្រីមាសទី៣។<br>- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធពលករទេសន្តរប្រវេសន៍ តាមរយៈ Telegram។<br>៧. <u>លេខាធិការដ្ឋាន គ.ខ.ប.ជ៖</u><br>❖ <u>ការងាររដ្ឋបាល ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨នេះ មានដូចខាងក្រោម:</u><br>- បានធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ប្រចាំខែ និងត្រីមាសទី៣)។ |

| | |
|---|---|
| | - បានរៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- បានបញ្ជូនរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅកាន់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។<br>- បានចងក្រង ព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដាក់ចូលក្នុងបណ្ណាសារវីគី និងគ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន ដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- បានស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ នៅរៀងរាល់កិច្ចប្រជុំ។<br>- បានបូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែ ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន៣៣លើក អ្នកចូលរួមសរុបចំនួន៤១៣នាក់ (ស្រី៣៥៩នាក់)** | |
| ខេត្តកណ្តាល | - ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដាចំនួន០៧លើក អ្នកចូលរួមចំនួន១៦២នាក់ ស្រី១០០នាក់។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ ទទួលជួបបទសម្ភាសន៍ ស្តីពីការងារបង្ការ ទប់ស្កាត់ និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើកុមារជាមួយអង្គការទស្សនពិភពលោក។<br>- ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ និងក្រុមការងារកិច្ចការអនុវត្តច្បាប់ បានចូលរួមធ្វើបទបង្ហាញ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពទៅក្រៅប្រទេស និងច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។<br>- លោកស្រី ឧត្តមសេនីយ៍ត្រី ស្នងការរង និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមក្នុងកិច្ចប្រជុំ ស្តីពីដំណើរការគ្រប់គ្រងករណីរួមគ្នារវាងប្រទេសកម្ពុជា និងប្រទេសថៃ នៅសណ្ឋាគារ ព្រីនសជីអង្គរ។<br>- រៀបចំកិច្ចប្រជុំតុមូលស្តីពី ការការពារសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីធឺណេត នៅសណ្ឋាគារសុខាល័យអង្គរ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ដោយមានការគាំទ្រពីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។<br>- រៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំការិយាល័យក្រុង ស្រុក ស្តីពីការងារបញ្ជ្រាបការផ្សព្វផ្សាយការទប់ស្កាត់ការជួញដូរកុមារ និងការជួញដូរមនុស្ស ពលកម្មកុមារ ដល់សិស្សានុសិស្ស អាណាព្យាបាល និង ប្រជាពលរដ្ឋ។ |
| ខេត្តកំពង់ឆ្នាំង | - គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក) បានរៀបចំកិច្ចប្រជុំប្រចាំខែសីហា ឆ្នាំ២០១៨ ចំនួន១០លើក វគ្គផ្សព្វផ្សាយបញ្ជ្រាប ស្តីពីការធ្វើចំណាកស្រុក ការជួញដូរស្ត្រី និងកុមារ អ្នកចូលរួមចំនួន១៩០នាក់ ស្រី១២៦នាក់ ឧបត្ថម្ភដោយអង្គការសង្គ្រោះ កុមារកម្ពុជា(Save the Children)។ |
| ខេត្តកំពង់ចាម | - បានចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សចំនួន០៣លើក៖<br>• ក្រោមអធិបតីភាព លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ<br>• ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ត្រី កែវ សុវណ្ណារ៉ា ប្រធាននាយកដ្ឋានបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br>• ក្រោមអធិបតីភាព លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា។ |

| | |
|---|---|
| ខេត្តរតនគិរី | - លោកជំទាវ គង់ ស៊ីផា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានដឹកនាំ គ.ខ.ប.ជ បានអញ្ជើញចូលរួមជាអធិបតីភាព ក្នុងវគ្គសិក្ខាសាលាចំនួន០២លើក៖<br>• ស្តីពីការផ្សព្វផ្សាយផែនការសកម្មភាព ការបង្ការ ទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះក្នុងវ័យជំទង់<br>• ស្តីពីអភិវឌ្ឍន៍កុមារតូច និងឪពុកម្តាយ។ |
| ខេត្តកោះកុង | - បានចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងារ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅបន្តនៅរាជធានីភ្នំពេញ។ |
| ខេត្តព្រៃវែង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ក្រោមអធិបតីភាព លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន៤៩នាក់ ស្រី៣២នាក់។ |
| ខេត្តព្រះវិហារ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំអំពីការពិភាក្សា ប្រធាន អនុប្រធាន សមាជិក ក្រុមការងារទាំង៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន២៥នាក់ ស្រី១២នាក់។ |
| ខេត្តក្រចេះ | - គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានរៀបចំកិច្ចប្រជុំ ស្តីពីការពង្រឹងតួនាទី ភារកិច្ច និងត្រៀមធ្វើរបាយការណ៍៩ខែ ដើមឆ្នាំ២០១៨ អ្នកចូលរួមចំនួន២៩នាក់ ស្រី១២នាក់។ |
| ខេត្តកែប | - លោកស្រី អភិបាលរងខេត្ត បានចូលរួមប្រជុំផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួម១២០នាក់ ស្រី៨៩នាក់។ |